**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ព្រះសីហនុ**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងលេខ ៖ ១២០
ចុះថ្ងៃទី ១៥.៩.២០២១
សាលដីកា
លេខ ៖ ១៥៣/១៩ ព្រទ.ក្រ
ចុះថ្ងៃទី ០៨.១២.២០២១

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍ព្រះសីហនុ**
បានបើកសវនាការជាសាធារណៈនៅសាលសវនាការ
នាថ្ងៃទី ២៣.១១.២០២១ ដោយមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**
លោកស្រី[redacted]ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោ[redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**
លោក[redacted]ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**
លោក[redacted]

**ដើម្បីជំនុំជំរះ ៖**

លើសំណុំរឿងសកាព្រហ្មទណ្ឌលេខ ៖ ១២០ ចុះថ្ងៃទី ១៥.៩.២០២១ ដែលមាន ៖

. ជនជាប់ចោទឈ្មោះ [redacted]ហួសានី ហៅ លីប ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរឥស្លាម មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិអ[redacted]ខេត្តព្រះសីហនុ សាសនា ព្រះពុទ្ធ នៅលីវ ឪពុកឈ្មោះ[redacted]" ម្តាយឈ្មោះ[redacted]" មានទីលំនៅបច្ចុប្បន្ននៅក្រុមទី ៧ ភូមិអូរគ្រាវ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កំរិតវប្បធម៌ ១២ ទោសពីមុន គ្មាន ។(**ដើមបណ្តឹងឧទ្ធរណ៍**)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៖ ១៩៧ តពដ/២០ ចុះថ្ងៃទី ២១.១១.២០២១

មានមេធាវីការពារសិទ្ធិ ៖ លោក[redacted]គីមយោង អត្តលេខ ១៨៣៣ ។

ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត នៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៦.១១.២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៦ ចំណុច ៤ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

<u>អង្គហេតុដាក់ឲ្យស្ថិតក្រោមការពិនិត្យ ៖</u>

កាលពីថ្ងៃទី ១៥.១១.២០២០ វេលាម៉ោង ១៥ និង ២៧នាទី កម្លាំងសមត្ថកិច្ចជំនាញកងរាជអាវុធហត្ថ ស្រុកព្រៃនប់ បានចុះឆែកឆេរបន្ទប់ជួលរបស់ឈ្មោះ [redacted]កាម៉ាល់ រកឃើញគ្រឿងញៀនប្រភេទម៉េ្យាសថ្លា ចំនួន ០១កញ្ចប់ ទម្ងន់ ០.៣៨ក្រាម ។ ក្រោយពីធ្វើការសាកសួរឈ្មោះខាងលើ នៅថ្ងៃទី ១៦.១១.២០២០ សមត្ថកិច្ច បានឃាត់ខ្លួនឈ្មោះ [redacted]ច័ន្ទរ៉ាយ៉ុន ម្នាក់ទៀត ដោយដកហូតបានគ្រឿងញៀនទម្ងន់ ៩៥.៤៦ក្រាម និងបានធ្វើ ការសាកសួរបន្តលើឈ្មោះនេះ បន្ទាប់មកកម្លាំងសមត្ថកិច្ចបានឈានទៅរកការឃាត់ខ្លួនឈ្មោះ[redacted]ហួសានី


អាសយដ្ឋាន៖ ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ទូរស័ព្ទ៖ ០៩៨ ៨៨១ ៩២៦ / ០១២ ៦៤៥ ៦០៣
Address: Village3, Sangkat 1, Preah Sihanouk City, Preah Sihanouk Province. Phone: 098 881 926 / 012 645 603

និងឈ្មោះ ហ៊ីម លី ដោយមានការជាប់ពាក់ព័ន្ធនឹងការសមគំនិតក្នុងការលក់គ្រឿងញៀន ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៖ ៤២៤/៤៥"ជ" ចុះថ្ងៃទី ០៥.៨.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចសេចក្តីថា ៖

១.កែប្រែបញ្ញត្តិមាត្រាចំពោះជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន មាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

២.កែប្រែបញ្ញត្តិមាត្រាចំពោះជនជាប់ចោទឈ្មោះ [redacted] ហួសានី និងឈ្មោះ [redacted] លី មាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មកបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

៣.ផ្តន្ទាទោសជនជាប់ចោទ ៖

៣.១.ឈ្មោ[redacted] ច័ន្ទរ៉ាយ៉ុន ភេទប្រុស អាយុ ២៩ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៨ឆ្នាំ និងពិន័យជាប្រាក់ ១៥,០០០,០០០(ដប់ប្រាំលាន)រៀល ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦.១១.២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច ៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.២.ឈ្មោះ [redacted] ហួសានី ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥ឆ្នាំ និងពិន័យជាប្រាក់ ១០,០០០,០០០(ដប់លាន)រៀល

៣.៣.ឈ្មោះ [redacted] លី ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥ឆ្នាំ និងពិន័យជាប្រាក់ ១០,០០០,០០០(ដប់លាន)រៀល ។

ពីបទសមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦.១១.២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច ៦ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣.៤.ឈ្មោះ [redacted] កាម៉ាល ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០២ឆ្នាំ ០៦ខែ ពីបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦.១១.២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.វត្ថុតាងរួមមាន ៖

៤.១.គ្រឿងញៀនមេតំហ្វេតាមីន ចំនួន ៩៥.៤៦ក្រាម ដែលដកហូតចេញពីឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន និងគ្រឿងញៀនមេតំហ្វេតាមីន ចំនួន ០.៣៨ក្រាម ដែលដកហូតពីឈ្មោះ [redacted] កាម៉ាល់ ដែកកេះចំនួន ០១ និងខ្សៀជក់ចំនួន ០១ តុលាការរឹបអូស និងបំផ្លាញចោល ។

៤.២.ទូរស័ព្ទចំនួន ០៤គ្រឿង និងប្រាក់ចំនួន ២៤០,០០០(ពីររយសែសិបពាន់)រៀល តុលាការរឹបអូស

Scanned with CamScanner

ជាទ្រព្យសម្បត្តិរដ្ឋ ។

៥.សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២១.៧.២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥.៨.២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ច័ន្ទរ៉ាយ៉ុន ឈ្មោះ [redacted] ហួសានី ឈ្មោះ [redacted]លី និងឈ្មោះ [redacted]កាម៉ាល់ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**បានឃើញ** សេចក្ដីសុំប្ដឹងឧទ្ធរណ៍លេខ ៖ ៨៦ ចុះថ្ងៃទី ១៧.៨.២០២១ របស់ឈ្មោះ [redacted] ហួសានី ជាជនជាប់ចោទ បានប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៖ ៤២៤/៤៥"ជ" ចុះថ្ងៃទី ០៥.៨.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ដោយមូលហេតុ សាលក្រមនេះមិនផ្ដល់ភាពយុត្តិធម៌ចំពោះរូបខ្លួន ។

**បានឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១១.១០.២០២១ ។

**បានឃើញ** សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ចុះថ្ងៃទី ២៦.១០.២០២១ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជំរះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted]ហួសានី ហៅ លីប ឆ្លើយថា ៖ ខ្លួនមិនបានប្រព្រឹត្តអំពើសមគំនិតជួញដូរគ្រឿងញៀនអ្វីទេ គឺគេឆ្លើយដាក់ខ្លួន តែបើប្រើប្រាស់គឺប្រើមែន ។ ក្នុងរឿងនេះ ខ្លួនគ្រាន់តែបានឲ្យលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនទៅឈ្មោះ រ៉ាយ៉ុន [redacted] ច័ន្ទរ៉ាយ៉ុន) ដោយមិនបានទទួលផលប្រយោជន៍ ឬកំរៃអ្វីពីឈ្មោះ រ៉ាយ៉ុន([redacted]ច័ន្ទរ៉ាយ៉ុន)ទេ ហើយឈ្មោះ រ៉ាយ៉ុន[redacted] ច័ន្ទរ៉ាយ៉ុន) បានទាក់ទងទៅអ្នកលក់គ្រឿងញៀនដើម្បីទិញគ្រឿងញៀនដោយខ្លួនឯង ។ ខ្លួនមានលេខអ្នកលក់គ្រឿងញៀននេះដោយបានមកពីមិត្តភក្តិ ។

ការប្រើប្រាស់គ្រឿងញៀន ខ្លួនប្រើយូរៗម្ដង ។

នៅថ្ងៃកើតហេតុ ខ្លួនបានទូរស័ព្ទទៅឈ្មោះ រ៉ាយ៉ុន[redacted]ច័ន្ទរ៉ាយ៉ុន) ដើម្បីខ្ចីម៉ូតូរបស់ឈ្មោះ រ៉ាយ៉ុន([redacted] ច័ន្ទរ៉ាយ៉ុន)ជិះ ហើយខ្លួនក៏ទៅផ្ទះរបស់ឈ្មោះ រ៉ាយ៉ុន([redacted]ច័ន្ទរ៉ាយ៉ុន)ជាមួយឈ្មោះ[redacted] លី ដើម្បីយកម៉ូតូ ទៅដល់ផ្ទះរបស់ឈ្មោះ រ៉ាយ៉ុន([redacted] ច័ន្ទរ៉ាយ៉ុន) ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្ដង ។ នៅថ្ងៃនោះ ឈ្មោះ រ៉ាយ៉ុន [redacted]ច័ន្ទរ៉ាយ៉ុន)មិនបានទូរស័ព្ទមកខ្លួនដើម្បីឲ្យខ្លួនទៅជួបទេ ហើយខ្លួនក៏មិនបានទទួលប្រាប់អ្វីពីឈ្មោះ រ៉ាយ៉ុន [redacted]ច័ន្ទរ៉ាយ៉ុន)ដែរ ។

**-តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា** ៖ ក្រោយពីបានស្ដាប់ការសួរដេញដោល ឃើញថាជនជាប់ចោទឈ្មោះ [redacted] ហួសានី បានឆ្លើយសារភាពថា ពិតជាបានឲ្យលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនទៅឈ្មោះ [redacted]ច័ន្ទរ៉ាយ៉ុន ហើយឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន នេះ ក្រោយពីបានលេខទូរស័ព្ទពីឈ្មោះ [redacted] ហួសានី ហើយ ក៏បានទាក់ទងទៅទិញថ្នាំញៀនតាមលេខទូរស័ព្ទនោះ និងទិញថ្នាំញៀនបានមែន ។ ដូចនេះ សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចតាមច្បាប់ ។

**-មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ**[redacted] ហួសានី **ធ្វើសេចក្ដីសន្និដ្ឋានការពារថា** ៖ យោងតាមអង្គហេតុក្នុងរឿងនេះឃើញថា កូនក្ដីខ្លួនឈ្មោះ [redacted]ហួសានី ពុំមានជាប់ពាក់ព័ន្ធនឹងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនទេ ដោយគាត់គ្រាន់តែមានលេខទូរស័ព្ទរបស់អ្នកលក់ថ្នាំញៀន ព្រោះគាត់ធ្លាប់ទិញ និងប្រើប្រាស់

គាត់ក៏ឲ្យលេខទូរស័ព្ទនោះទៅឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ហើយឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ជាអ្នកទាក់ទងទៅទិញថ្នាំញៀននោះដោយខ្លួនឯង ហើយកូនក្តីខ្លួនពុំបានទទួលផលប្រយោជន៍ ឬកំរៃអ្វីពីការទិញលក់នោះទេ ។ ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ហួសានី រួចផុតពីបទចោទ បទសមគំនិតក្នុងអំពើជួយជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

-ជនជាប់ចោទឈ្មោះ [redacted] ហួសានី និយាយសំដីកត់សំគាល់ចុងក្រោយថា ៖ សូមសាលាឧទ្ធរណ៍ជួយរកយុត្តិធម៌ឲ្យខ្លួនផង ។

ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីបានស្តាប់សំដីកត់សំគាល់ចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## **យល់ឃើញថា ៖**

-សេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ៖ ៨៦ ចុះថ្ងៃទី ១៧.៨.២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ហួសានី ហៅ លីប បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៖ ៤២៤/៤៥"ជ" ចុះថ្ងៃទី ០៥.៨.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឡើងក្នុងកំណត់ច្បាប់ ។ ដូច្នេះ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-តាមសាលក្រមព្រហ្មទណ្ឌលេខ ៖ ៤២៤/៤៥"ជ" ចុះថ្ងៃទី ០៥.៨.២០២១ ឈ្មោះ [redacted] ហួសានី ហៅ លីប ត្រូវជាប់ចោទពីបទសមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា និងថ្ងៃទី ១៦.១១.២០២០ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៦ ចំណុច ៤ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៥ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០រៀល ពីបទចោទខាងលើ តាមមាត្រា ៤០ កថាខណ្ឌ ៥ ចំណុច ៦ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

-តាមចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហួសានី បានឆ្លើយថា ខ្លួនមិនប្រព្រឹត្តអំពើសមគំនិតក្នុងការជួញដូរគ្រឿងញៀនទេ តែបើប្រើប្រាស់ គឺប្រើមែន ។ ក្នុងរឿងនេះ ខ្លួនគ្រាន់តែបានឲ្យលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនទៅមិត្តភក្តិឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ហើយឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ជាអ្នកទាក់ទងទិញគ្រឿងញៀនដោយខ្លួនឯង ដោយខ្លួនមិនបានទទួលផលកំរៃអ្វីពីការទិញលក់នេះទេ ។ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ដែលបានឆ្លើយថា កាលពីថ្ងៃទី ១៦.១១.២០២០ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ង៉ុក ក្នុងតម្លៃ ១,០០០ដុល្លាអាមេរិក ដោយបានលេខទំនាក់ទំនងពីឈ្មោះ [redacted] ហួសានី ។ ខ្លួនបានផ្ញើលុយតាមវីងចំនួន ៨០០ដុល្លាអាមេរិកឲ្យទៅឈ្មោះ ង៉ុក និងសល់ ២០០ដុល្លាអាមេរិកទៀត ខ្លួននឹងឲ្យទៅឈ្មោះ [redacted] ហួសានី ។ ខ្លួនបានបែងចែកគ្រឿងញៀនជា ០៣កញ្ចប់ ក្នុង ០១កញ្ចប់ តម្លៃ ៥០០ដុល្លាអាមេរិក ។

-អំពើឲ្យលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនឲ្យទៅឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ដើម្បីទិញគ្រឿងញៀងយកមកលក់បន្ត និងទទួលបានប្រាក់កំរៃរបស់ឈ្មោះ [redacted] ហួសានី គឺជាបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុ ។ ដោយឡែក ចំពោះអំពើប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ជនជាប់ចោទឈ្មោះ [redacted] ហួសានី បានឆ្លើយសារភាពហើយ ។

ដូចនេះ សាលក្រមព្រហ្មទណ្ឌលេខ ៖ ៤២៤/៤៥"ជ" ចុះថ្ងៃទី ០៥.៨.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ សម្រេចសេចក្តីត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះទុកជាបានការដដែល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៖ ៨៦ ចុះថ្ងៃទី ១៧.៨.២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ហួសានី ទុកជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៖ ៤២៤/៤៥"ជ" ចុះថ្ងៃទី ០៥.៨.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៣.១១.២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៨.១២.២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហួសានី ។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] - [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ព្រះសីហនុ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]

[redacted]



Scanned with CamScanner